# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

<u>សេចក្តីប្រកាសពត៌មាន</u>

# ការប្រកាសបើកកម្មវិធីអាហារូបករណ៍សំរាប់ទៅសិក្សា នៅប្រទេសអូស្ត្រាលីក្នុងឆ្នាំក្រោយ

នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០១៥ ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា លោកជំទាវ **អាលីសុន បើររ៉ូ** និងឯកឧត្តមបណ្ឌិត **សាយ សំអាល់** រដ្ឋមន្ត្រីនៃក្រសួងបរិស្ថាន បានរួមគ្នាប្រកាសបើកជាផ្លូវការនូវកម្មវិធីអាហារូបករណ៍អូស្ត្រាលី ដើម្បីបន្តការសិក្សានៅប្រទេសអូស្ត្រាលីក្នុងឆ្នាំក្រោយ។

លោកជំទាវឯកអគ្គរាជទូត បើររ៉ូ បានលើកទឹកចិត្តដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ដែលចាប់អារម្មណ៍នឹងកម្មវិធីអាហារូបករណ៍នេះ អោយចូលរួមដាក់ពាក្យប្រលងដើម្បីទទួលបានអាហារូបករណ៍អូស្ត្រាលី។

លោកជំទាវបានមានប្រសាសន៍ថា៖ "ការអប់រំនៅប្រទេសអូស្ត្រាលី គឺជាមធ្យោបាយដ៏មានប្រសិទ្ធិភាពសំរាប់ប្រជាពលរដ្ឋកម្ពុជាដែលមានទេពកោសល្យ។ អូស្ត្រាលីមានសកលវិទ្យាល័យមួយចំនួន ដែលជាប់ចំណាត់ថ្នាក់ជាសកលវិទ្យាល័យដែលល្អផ្តាច់គេនៅក្នុងពិភពលោក។ ការសិក្សាពីប្រទេសអូស្ត្រាលី អាចផ្តល់ជំនាញនិងចំណេះដឹងបន្ថែមដែលអ្នកត្រូវការសំរាប់ធ្វើការកែប្រែនិងអភិវឌ្ឍនៅក្នុងប្រទេសរបស់អ្នក"។

លោកជំទាវឯកអគ្គរាជទូត បើររ៉ូ និងឯកឧត្តមបណ្ឌិត សាយ សំអាល់ ក៏បានស្វាគមន៍នូវការវិលត្រលប់មកកាន់មាតុភូមិវិញនៃនិស្សិតកម្ពុជាចំនួន៥៣រូប ដែលបានទទួលអាហារូបករណ៍អូស្ត្រាលី ហើយបញ្ចប់ការសិក្សាកាលពីឆ្នាំ២០១៤ ពីបណ្តាសកលវិទ្យាល័យនានានៅអូស្ត្រាលី លើមុខវិជ្ជាផ្សេងៗ រួមមាន ចាប់តាំងពីផ្នែកពន្ធដាររហូតដល់ផ្នែកបច្ចេកវិជ្ជាជីវៈសាស្ត្រ។ លោកជំទាវឯកអគ្គរាជទូត ក៏បានលើកទឹកចិត្តដល់និស្សិតដែលទើបតែបញ្ចប់ការសិក្សា អោយប្រើប្រាស់ជំនាញថ្មីៗរបស់ពួកគេនៅកម្ពុជា។

ការដាក់ពាក្យប្រលងអាហារូបករណ៍អូស្ត្រាលី ដើម្បីទៅសិក្សាថ្នាក់ក្រោយឧត្តមនៅប្រទេសអូស្ត្រាលីនាឆ្នាំ២០១៦ នឹងចាប់ផ្តើមបើកទទួលចាប់ពីពេលនេះតទៅ ហើយនឹងបិទទៅវិញនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៥។ អាហារូបករណ៍អូស្ត្រាលី នឹងផ្តល់ជូនទៅបុគ្គលឆ្នើមដើម្បីសិក្សាលើ

16B National Assembly Street, Sangkat Tonle Bassac Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

មុខជំនាញនានា ដែលរួមចំណែកក្នុងកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ កម្មវិធីអាហារូបករណ៍អូស្ត្រាលីក្នុងវគ្គនេះ នឹងផ្តោតសំខាន់លើវិស័យៈ ហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម សុខាភិបាល ការគ្រប់គ្រងវិស័យអប់រំ ពាណិជ្ជកម្ម និងមុខវិជ្ជាទាំងឡាយណាដែលអាចជួយកាត់បន្ថយអំពើហិង្សាទៅលើស្ត្រី។

អាហារូបករណ៍អូស្ត្រាលី បានផ្តល់ដោយរដ្ឋាភិបាលអូស្ត្រាលីជារៀងរាល់ឆ្នាំ ដល់អនាគតអ្នកដឹកនាំពិភពលោកជំនាន់ក្រោយសំរាប់ការអភិវឌ្ឍន៍។ សកលវិទ្យាល័យអូស្ត្រាលី ត្រូវបានទទួលស្គាល់ថាជាប់ចំណាត់ថ្នាក់ក្នុងចំណោមសកលវិទ្យាល័យល្អផ្តាច់គេនៅលើពិភពលោក ហើយតាមរយៈការសិក្សានិងការស្រាវជ្រាវ និស្សិតទទួលអាហារូបករណ៍អូស្ត្រាលីនឹងអភិវឌ្ឍនូវជំនាញនិងចំណេះដឹងដែលសំខាន់សំរាប់ដឹកនាំអោយមានរីកចម្រើនដល់សហគមន៍របស់ពួកគេ។ បន្ថែមលើឱកាសដែលបានទៅសិក្សានៅក្នុងសកលវិទ្យាល័យដែលមានគុណភាពខ្ពស់ និស្សិតអាហារូបករណ៍ក៏មានឱកាសក្នុងការរាប់អានមិត្តភ័ក្រថ្មីៗ និងអាចកសាងនូវចំណងមិត្តភាពយូរអង្វែងជាមួយដៃគូអូស្ត្រាលី។

រដ្ឋាភិបាលអូស្ត្រាលីមានការប្តេជ្ញាចិត្ត ក្នុងការផ្តល់ឱកាសជូនដល់មនុស្សគ្រប់គ្នា ហើយយើងលើកទឹកចិត្តដល់ស្ត្រី ជនពិការ និងអ្នកដែលមកពីតាមបណ្តាខេត្តនានា ក្នុងការដាក់ពាក្យប្រលងយកអាហារូបករណ៍អូស្ត្រាលី។ ក្នុងឱកាសទិវាសិទ្ធិនារីអន្តរជាតិដែលកំពុងតែខិតចូលមកដល់ យើងក៏សូមលើកចិត្តជាពិសេសដល់ស្ត្រីក្នុងការដាក់ពាក្យផងដែរ។ កម្មវិធីអាហារូបករណ៍អូស្ត្រាលី បើកទទួលពាក្យពីបេក្ខជនដែលមកពីបណ្តាស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងវិស័យឯកជន។

ព័ត៌មានបន្ថែមអំពីអាហារូបករណ៍អូស្ត្រាលី សូមចូលទៅវេបសាយ www.australiaawards.gov.au
ទំនាក់ទំនងព័ត៌មានៈ លោក **សាយម៉ុន ហ៊ើលឡូវាស់** អនុប្រធានបេសកកម្ម
ស្ថានទូតអូស្ត្រាលី ភ្នំពេញ
ទូរស័ព្ទលេខ ០២៣ ២១៣ ៤៧០
ភ្នំពេញថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥